# ក្រុមមេធាវីការពារក្តី មាស មុត
# MEAS MUTH DEFENCE TEAM
# EQUIPE DE DEFENSE DE MEAS MUTH

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Aug-2014, 08:46
CMS/CFO: Sann Rada

**អាង ឧត្តម** និង **Michael G. KARNAVAS**
សហមេធាវីការពារក្តីលោក មាស មុត
ថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៤

គោរពជូន៖ លោកចៅក្រម **យូ ប៊ុនឡេង**
លោកចៅក្រម **Mark HARMON**
សហចៅក្រមស៊ើបអង្កេត

កម្មវត្ថុ៖ សំណើសុំព័ត៌មានទាក់ទងនឹងសុពលភាពនៃដីកាកោះ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់

គោរពជូនចំពោះសហចៅក្រមស៊ើបអង្កេត៖

យើងខ្ញុំសូមគោរពស្នើសុំព័ត៌មានទាក់ទងនឹងសុពលភាពនៃដីកាកោះ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ក្នុងគោលបំណងចោទប្រកាន់លោក មាស មុត។

លោកចៅក្រមបានចុះកំណត់ត្រាយ៉ាងតិចក៏ចំនួនពីរដងដែរ អំពីការខ្វែងយោបល់គ្នាទាក់ទងនឹងរឿងក្តី ០០៣[1]។ លោកចៅក្រម យូ ប៊ុនឡេង បានបញ្ជូនសំណុំរឿងរួចរាល់ហើយទៅឱ្យសហព្រះរាជអាជ្ញា ដើម្បីចេញសេចក្តីសន្និដ្ឋានស្ថាពរ ដោយមិនចោទប្រកាន់លោក មាស មុត[2] ហើយចាប់តាំងពីពេលនោះមក (តាមដែលមេធាវីការពារក្តីបានដឹង) លោកចៅក្រមមិនបានបំពេញការងារជាមួយគ្នាឡើយនៅក្នុងការសម្រេចសេចក្តី ដីកា ឬ ការទំនាក់ទំនងឆ្លើយឆ្លងគ្នាណាមួយ ដែលបានចេញក្នុងរឿងក្តី ០០៣។

---

[1] *សូមមើល* ការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យ សុំចូលពិនិត្យមើលសំណុំរឿង និង ចូលរួមការស៊ើបអង្កេតតាមផ្លូវតុលាការ (D82) និង សុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង សម្ភារៈគាំទ្រ (D82/2) ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D82/3 ។ ការជូនដំណឹងនេះបានយោងការខ្វែងយោបល់គ្នាដែលបានដាក់កាលពីថ្ងៃទី ០៧ និង ទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[2] *សូមមើល* សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតទាក់ទងរឿងក្តី ០០៣ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

ប្រសិនបើលោកចៅក្រម Harmon កោះហៅលោក មាស មុត ជាឯកតោភាគី (ដូចដែលបានកើតឡើងក្នុងរឿង ០០៤[3]) នោះ យើងខ្ញុំនឹងត្រូវការសំអាងហេតុផ្លូវច្បាប់របស់សហចៅក្រមស៊ើបអង្កេតម្នាក់ៗទាក់ទងនឹងសុពលភាពនៃដីកាកោះនោះ។ យើងខ្ញុំមិនអាចផ្ដល់ប្រឹក្សាប្រកបដោយអត្ថន័យជូនលោក មាស មុត ដោយមិនមានសំអាងហេតុផ្លូវច្បាប់នេះឡើយ។ ការប្ដឹងឧទ្ធរណ៍អាចចាំបាច់ត្រូវធ្វើឡើង ហើយអង្គបុរេជំនុំជម្រះនឹងជួបប្រទះបញ្ហាក្នុងការសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍នេះ ប្រសិនបើសេចក្ដីសម្រេចនេះមិនមានសំអាងហេតុទេនោះ[4]។

សុពលភាពនៃដីកាកោះដែលត្រូវបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ មិនត្រូវបានកំណត់ឲ្យបានច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. និង វិធានផ្ទៃក្នុងឡើយ។ នៅក្នុងរឿងក្ដី ០០២ មានពីរករណីដែលសហចៅក្រមស៊ើបអង្កេតមានការខ្វែងយោបល់គ្នា ប៉ុន្តែមិនមានករណីណាមួយដែលត្រូវនឹងបញ្ហាដែលកំពុងមាននេះឡើយ។ ករណីទីមួយ សហចៅក្រមស៊ើបអង្កេត Lemonde បានចេញដីកាតែម្នាក់ឯង កោះហៅព្រះវររាជបីតា និង មន្ត្រីរដ្ឋាភិបាលមួយចំនួនមកធ្វើជាសាក្សី។ អង្គបុរេជំនុំជម្រះបានច្រានចោលទឡ្ហីករណ៍ដែលលើកថា ការបំពេញកិច្ចដែលបានធ្វើឡើងដោយចៅក្រម Lemonde មិនមានសុពលភាព ដោយសារដីកាកោះនៅពេលនោះមិនមានហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេតជាតិ[5]។ ប៉ុន្តែ ស្ថានភាពនៅពេលនោះគឺខុសពីពេលនេះ ព្រោះថា ការកោះហៅសាក្សីជា

[3] *សូមមើល* សុខ ខេមរា *ជនសង្ស័យខ្មែរក្រហមបន្ថែមទៀត ដែលត្រូវបង្ហាញខ្លួននៅអង្គជំនុំជម្រះនៅថ្ងៃច័ន្ទ* វិទ្យុសម្លេងសហរដ្ឋអាមេរិក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ អាចរកបាននៅ http://www.voacambodia.com/content/additional-khmer-rouge-suspect-to-appear-at-tribunal-monday/2409141.html។

[4] *សូមមើល* រឿងក្ដី នួន ជា និង អ្នកដទៃទៀត សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ" ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ២៩ ដែលអង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្ដីសន្និដ្ឋានដែលមិនមានសំអាងហេតុនេះ មិនអាចឲ្យអង្គបុរេជំនុំជម្រះអនុវត្តភារកិច្ចរបស់ខ្លួនក្នុងការពិនិត្យឲ្យមានប្រសិទ្ធភាពទៅលើសេចក្ដីសម្រេចនោះ ហើយរារាំងអង្គបុរេជំនុំជម្រះមិនឲ្យអាចកំណត់ពីការអនុវត្តត្រឹមត្រូវទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតទេ។

[5] *សូមមើល* រឿងក្ដី នួន ជា និង អ្នកដទៃទៀត សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧៥ យោង *រឿងក្ដី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០ និង ៥១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំឲ្យកោះហៅសាក្សី ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D314/1/8។

មន្ត្រីរដ្ឋាភិបាលគឺពាក់ព័ន្ធនឹងការស៊ើបអង្កេតតាមផ្លូវតុលាការ ហើយកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. បានចែងថា ក្នុងករណីដែលមានការខ្វែងយោបល់គ្នា *ការស៊ើបអង្កេតត្រូវបន្តអនុវត្ត*[6]។ ការកោះហៅលោក មាស មុត ដើម្បីធ្វើការចោទប្រកាន់ *មិន* ពាក់ព័ន្ធនឹងបញ្ហាថាតើការស៊ើបអង្កេតនឹងត្រូវបន្ត ឬយ៉ាងណានោះឡើយ ព្រោះការកោះហៅនេះមិនមែនជាកិច្ចស៊ើបអង្កេតទេ។ ករណីទីពីរ សហចៅក្រមស៊ើបអង្កេតមានការខ្វែងយោបល់គ្នាអំពីបញ្ហាថាតើត្រូវចោទប្រកាន់ជនជាប់ចោទ ដោយប្រើបទល្មើសជាតិ ឬយ៉ាងណា ប៉ុន្តែ *ពួកគាត់បានឯកភាពរួមគ្នា* ដាក់បញ្ចូលបទល្មើសជាតិទៅក្នុងដីកាដំណោះស្រាយ ហើយទុកបញ្ហានេះឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការដោះស្រាយ[7]។ ករណីនេះមិនអាចយកមកអនុវត្តបានទេ ចំពោះស្ថានភាពដែលមានសហចៅក្រមស៊ើបអង្កេតតែមួយរូបគត់ជាអ្នកចេញដីកាកោះហៅជនសង្ស័យ។

រហូតមកដល់ពេលនេះ អង្គបុរេជំនុំជម្រះមិនទាន់ត្រូវបានស្នើសុំឱ្យជួយដោះស្រាយនៅឡើយទេ នូវការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដែលមិនពាក់ព័ន្ធនឹងបញ្ហាថាតើការចោទប្រកាន់[8] ឬការស៊ើបអង្កេតត្រូវបន្តទៅមុខឬយ៉ាងណានោះ។

យើងខ្ញុំសូមថ្លែងអំណរគុណាបើចម្លើយដ៏ឆាប់រហ័សត្រូវបានផ្តល់ឱ្យ ដើម្បីឱ្យយើងខ្ញុំអាចបំពេញកាតព្វកិច្ចផ្នែកវិជ្ជាជីវៈ និង ផ្នែកក្រមសីលធម៌របស់យើងខ្ញុំ ក្នុងនាមជាមេធាវីការពារក្តីលោក មាស មុត ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់។

សូមលោកចៅក្រមទទួលយកលិខិតនេះដោយក្តីគោរពអំពីយើងខ្ញុំ។

សហមេធាវីការពារក្តីលោក មាស មុត

អាង ឧត្តម Michael G. KARNAVAS

[6] មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[7] *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ១៥៧៤។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧២-២៧៧។

[8] អង្គបុរេជំនុំជម្រះត្រូវបានស្នើសុំឱ្យធ្វើការសម្រេចថា តើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអាចត្រូវបានដាក់ដើម្បីបើករឿងក្តី ០០៣ និង ០០៤ ឬយ៉ាងណា។ សំណុំរឿងលេខ ០០១/១៨-១១-២០០៨ អ.វ.ត.ក/អ.ប.ជ ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩។ មាត្រា ៦(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. និង មាត្រា ២០ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. បានចែងថា ក្នុងករណីមានការខ្វែងយោបល់គ្នា ការចោទប្រកាន់ត្រូវបន្តទៅមុខ។